# គណបក្ស សិទ្ធិមនុស្ស
## HUMAN RIGHTS PARTY

បំរើ ការពារ កសាង


លេខ..០០៤០/០៩...គ.ស.ម

ភ្នំពេញ, ថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០០៩

# សេចក្តីថ្លែងការណ៍

**គណបក្សសិទ្ធិមនុស្ស** មានសេចក្តីក្រៀមក្រំយ៉ាងខ្លាំងក្រោយពីបានទទួលពត៌មានថាលោក **ស៊ីម ឈេត** អាយុ៤៨ឆ្នាំ ដែលជាសកម្មជនដ៏មានប្រជាប្រិយរបស់គណបក្សសិទ្ធិមនុស្ស នៅឃុំកណ្តុរជ្រំ ស្រុកពញាក្រែក ខេត្តកំពង់ចាម បានត្រូវឃាតករបាញ់សំលាប់យ៉ាងឃោរឃៅទៅលើរូបលោក កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោងប្រមាណ១២យប់ ខណៈដែលគាត់កំពុងជិះម៉ូតូតាមដងផ្លូវធ្វើដំណើរទៅផ្ទះគាត់ ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា នេះជាអំពើឃាតកម្មយ៉ាងសាហាវព្រៃផ្សៃ ដែលបានរំលោភយ៉ាងធ្ងន់ធ្ងរ លើសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួនរបស់បុគ្គល និងសិទ្ធិនយោបាយ របស់លោក **ស៊ីម ឈេត** ។ មិនតែប៉ុណ្ណោះឃាតកម្មនេះបានបង្កឱ្យមានការភ័យខ្លាចនៅក្នុងអារម្មណ៍សកម្មជននយោបាយក៏ដូចជាប្រជាពលរដ្ឋខ្មែរទូទៅផងដែរ ។

**គណបក្សសិទ្ធិមនុស្ស** ថ្កោលទោសយ៉ាងខ្លាំងចំពោះក្រុមឃាតករ និងអ្នកសមគំនិត និងសូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ច ស្វែងរកចាប់ឃាតករពិតឱ្យបានដើម្បីផ្តន្ទាទោស រកយុត្តិធម៌ជូនជនរងគ្រោះ និងគ្រួសារព្រមទាំងបំបាត់ចោលឱ្យអស់នូវទម្រង់និទណ្ឌភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**អគ្គលេខាធិការដ្ឋានគណបក្សសិទ្ធិមនុស្ស**

ពត៌មានបន្ថែមសូមទាក់ទង

ទូរស័ព្ទ : ០១២ ៤០០ ០២៦